TECHNICAL DATA SHEET

# VINILEX 5000 WALL SEALER

**Vinilex 5000 Wall Sealer** គឺជាថ្នាំ ប្រភេទ **acrylic** ដែលមានមូលដ្ឋានជាទឹក។ វាមានភាពងាយស្រួលក្នុងការលាប និងមានសម្ថភាពដ៏ស្អិតល្អក្នុងការខាំជាប់និងផ្ទៃ។

**Product Features:**

- VOC ទាប
- ក្លិនទាប
- ងាយស្រួលលាប និងប៉ះ
- ធន់នឹងការប្រេឡាក់
- លំហូរល្អឥតខ្ចោះ
- គ្មានជាតិពុល និងគ្មានសារធាតុសំណ បារត និងលោហធាតុធ្ងន់
- ធន់នឹងស្លែរ និងផ្សិត
- ថ្នាំលាបដែលមានវិញ្ញាបនបត្រ Singapore Green Building Product Certification Scheme

| ប្រភេទថ្នាំ | ផ្នែកលាប | សំរេច | ផ្ទៃលាប | បរិមាណ |
|---|---|---|---|---|
| Acrylic Polymer Emulsion | ផ្នែកខាងក្នុង | **Matt** | ម្នាងសិលា, ស៊ីម៉ងត៍, បេតុង, ឈើ, ដែក, ជញ្ជាំងបូក | 5 លីត្រ |

## ទិន្នន័យនៃការលាប

**ឧបករណ៍ប្រើប្រាស់** : ជក់, រ៉ូឡូ និង ម៉ាស៊ីនបាញ់ខ្យល់។

**ប្រវែងអាចលាបបាន** : ទ្រឹស្តុ: 13.0 ម$^2$/ លីត្រ (ផ្អែកលើ 30 microns DFT)

**ល្បាយលាយ** : មិនចាំបាច់លាយដើម្បីដំណើរការល្អបំផុតទេ

## ការរៀបចំផ្ទៃ

ត្រូវប្រាកដថាផ្ទៃស្អាត ស្ងួត និងមានស្ថេរភាព

**សំណើម** : មិនត្រូវមានសំណល់ទឹកនៅលើផ្ទៃនៃស្រទាប់ខាងក្រោម។
សំណើមត្រូវតែមាននៅក្រោម <4% (Sovereign moisture master) មុនពេលលាប។

**ស្រទាប់មិនស្អិតស្អេ** : យកស្រទាប់ស្អិតរលុង ធូលីដី ថ្នាំលាបដែលរបកចេញជាដើម ចេញដោយប្រើទឹកបាញ់សម្ពាធខ្ពស់ ឬមធ្យោបាយមេកានិចដូចជាច្រាស់ដុះ ឬកាំបិតឈូស អាស្រ័យលើជម្រើសដែលសមស្រប។

**សារធាតុកខ្វក់** : សម្អាតធូលី និងសារធាតុដែលកខ្វក់ចេញជាមួយនឹងក្រណាត់សើម។ យកប្រេង ឬខ្លាញ់ចេញដោយប្រើសារធាតុរំលាយ ឬសាប៊ូ។ ទុកឱ្យផ្ទៃស្ងួត។

**ស្លែរនិងផ្សិត** : សម្អាតដោយកាំបិតឈូស ហើយត្រូវប្រើជាមួយ NIPPON ANTI-FUNGUS SOLUTION។
លាងសម្អាតម្តងទៀតដោយទឹកស្អាត  ហើយទុកអោយស្ងួត។

**ស្នាមប្រេះ** : បំពេញស្នាមប្រេះជាមួយនឹងសារធាតុបំពេញដែលមានសារធាតុរំលាយ ឬសារធាតុមិនរលាយក្នុងទឹក។

## ព័ត៌មានទូទៅ

**SOLID CONTENT** : 56.0 ± 2.0% តាមទម្ងន់ (ផ្អែកលើពណ៌ស)

**ទម្ងន់ជាក់លាក់** : 1.39 ± 2.0 % kg / litre តាមទម្ងន់ (ផ្អែកលើពណ៌ស)

**ការផ្ទុក** : ទុកក្នុងធុងបិទជិតមួយកន្លែង ក្នុងកន្លែងត្រជាក់ និងស្ងួត

**អាយុកាល** : រហូតដល់ 24 ខែក្នុងធុងបិទជិត

## ការប្រុងប្រយ័ត្ន

- បិទធុងឱ្យជិត ហើយទុកឱ្យឆ្ងាយពីកុមារ ឬឆ្ងាយពីអាហារ និងភេសជ្ជៈ។
- ធានាឱ្យមានខ្យល់ចេញចូលល្អក្នុងពេលលាប និងសម្ងួត។
- អំឡុងពេលលាបថ្នាំលាប មិនត្រូវអនុញ្ញាតឱ្យមានអណ្តាតភ្លើង ប្រតិបត្តិការផ្សារដែក និងការជក់បារីឡើយ។
- ពេលលាបថ្នាំលាប គួរតែពាក់ឧបករណ៍ការពារភ្នែក។
- ក្នុងករណីប៉ះពាល់នឹងភ្នែក សូមលាងសម្អាតជាមួយទឹកឱ្យបានច្រើនភ្លាមៗ ហើយស្វែងរកការព្យាបាលពីគ្រូពេទ្យ។
- យកស្នាមប្រឡាក់ចេញពីស្បែកដោយប្រើសាប៊ូ ឬទឹក។
- ថ្នាំលាបត្រូវតែរក្សាទុកក្នុងកន្លែងត្រជាក់ជានិច្ច។
- ពេលដឹកជញ្ជូនថ្នាំលាប ត្រូវប្រុងប្រយ័ត្ន។ តែងតែទុកកុងតឺន័រឱ្យត្រង់។
- បោះចោលកាកសំណល់ថ្នាំលាបណាមួយស្របតាមបទប្បញ្ញត្តិគុណភាពបរិស្ថានសមស្រប។

## ចំណាំ

ព័ត៌មានដែលបានផ្តល់ឱ្យអនុវត្តចំពោះផលិតផល និងដំណើរការរបស់វាក្រោមលក្ខខណ្ឌធ្វើតេស្តសាកល្បងជាក់ស្តែង។ ដោយសារកាលៈទេសៈប្រែប្រួលហួសពីការគ្រប់គ្រងរបស់យើង ដែលផលិតផលអាចត្រូវបានអនុវត្ត សម្រាប់វិធីសាស្ត្រនៃការលាបជាក់លាក់ សូមទាក់ទងផ្នែកលក់ និងទីផ្សារនៃ JCM Nippon Paint ( Cambodia ) Co. Ltd. យើងរក្សាសិទ្ធិក្នុងការកែប្រែតារាងទិន្នន័យផលិតផលរបស់យើងដោយមិនមានការជូនដំណឹងបន្ថែម។